ASIAN DEVELOPMENT BANK
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel + 63 2 632 4444
Fax + 63 2 636 4444

www.adb.org

NEWS RELEASE

# តម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធរបស់អាស៊ីកើនឡើងលើសពី ១,៧ ទ្រីលានដុល្លារ ក្នុងមួយឆ្នាំ ពេលគិតគូរនៃតួលេខប៉ាន់ប្រមាណកន្លងមក

ហុងកុង សាធារណៈរដ្ឋប្រជាមានិតចិន (ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧) - តម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ តាមប្រទេសកំពុងអភិវឌ្ឍ នៅអាស៊ី និងប៉ាស៊ីហ្វិច នឹងកើនឡើងលើសពី ២២,៦ ទ្រីលានដុល្លារ រហូតដល់ឆ្នាំ ២០៣០ ឬ ១,៥ ទ្រីលានដុល្លារ ក្នុងមួយឆ្នាំ ប្រសិនបើតំបន់នេះមានបំណងចង់បន្តរក្សាកំណើនដែលសម្រេចបានកន្លងមក នេះបើតាមរបាយការណ៍ថ្មីមួយ ដែលចេញផ្សាយដោយធនាគារអភិវឌ្ឍន៍អាស៊ី (ហៅកាត់ថា ADB)។ តួលេខប៉ាន់ប្រមាណនេះកើនឡើងដល់ជាង ២៦ ទ្រីលានដុល្លារ ឬ ១,៧ ទ្រីលានដុល្លារ ក្នុងមួយឆ្នាំ នៅពេលគេគិតបញ្ចូលទាំងចំណាយសម្រាប់ការកាត់បន្ថយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុផងនោះ។

របាយការណ៍ ក្រោមចំណងជើងថា*ការបំពេញតម្រូវការហេដ្ឋារចនាសម្ព័ន្ធនៅអាស៊ី* ផ្តោតការយកចិត្តទុកដាក់លើហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងថាមពល គមនាគមន៍ ទូរគមនាគមន៍ ទឹកស្អាត និងអនាម័យ ក្នុងតំបន់នេះ។ របាយការណ៍នេះធ្វើការពិនិត្យគ្រប់ជ្រុងជ្រោយលើចំនួនហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលកំពុងមាននាពេលបច្ចុប្បន្ន តម្រូវការវិនិយោគសម្រាប់ពេលអនាគត និងយន្តការផ្តល់ហិរញ្ញប្បទានដល់ប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី។

លោក Takehiko Nakao ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី មានប្រសាសន៍ថា "តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ក្នុងអាស៊ី និងប៉ាស៊ីហ្វិចទាំងមូល គឺមានលើសពីសមត្ថភាពផ្គត់ផ្គង់បច្ចុប្បន្ន។ អាស៊ីត្រូវការហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ល្អប្រសើរជាងមុន ដែលនឹងដាក់ចេញនូវស្តង់ដាគុណភាព ជម្រុញកំណើនសេដ្ឋកិច្ច និងឆ្លើយតបចំពោះបញ្ហាប្រឈមបន្ទាន់របស់សកលលោកទាំងមូល ពោលគឺការប្រែប្រួលអាកាសធាតុ។"

**Media Inquiries**

Erik Churchill
Tel: (632) 6831905
Mob: (63) 999 999 1905
E-mail: echurchill@adb.org

**Connect with us on Twitter @ADB_HQ**

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្នុងប្រទេសចំនួន ៤៥ ប្រទេស ដែលត្រូវបានគ្របដណ្តប់ក្នុងរបាយការណ៍នេះ មានការកើនឡើងយ៉ាងគំហ៊ុក ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ជាកត្តាជម្រុញកំណើន កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែ នៅតែមានការខ្វះហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដូចជា មនុស្សជាង ៤០០ លាននាក់ នៅមិនទាន់មានអគ្គិសនីប្រើប្រាស់ ៣០០ លាននាក់ នៅមិនទាន់មានទឹកស្អាតសម្រាប់ប្រើប្រាស់ និងប្រមាណជា ១,៥ ពាន់លាននាក់ នៅខ្វះលទ្ធភាពទទួលបានសេវាអនាម័យជាមូលដ្ឋាន។ ប្រទេសជាច្រើនក្នុងតំបន់នេះ នៅខ្វះកំពង់ផែ ផ្លូវដែក និងផ្លូវថ្នល់ ដែលអាចភ្ជាប់ទំនាក់ទំនងពួកគេបានយ៉ាងមានប្រសិទ្ធភាព ជាមួយនឹងទីផ្សារធំៗទាំងក្នុងប្រទេស ទាំងក្នុងសកលលោកទាំងមូល។

លោក Nakao មានប្រសាសន៍ថា "ADB ប្តេជ្ញាថានឹងធ្វើការងារជាមួយប្រទេសជាសមាជិក ក៏ដូចជាប្រើប្រាស់បទពិសោធន៍ និងជំនាញឯកទេសរយៈពេល ៥០ ឆ្នាំរបស់យើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធ ក្នុងតំបន់នេះ។ ដោយសារតែវិស័យឯកជនមានតួនាទីសំខាន់ ក្នុងការបំពេញចន្លោះខ្វះខាតខាងហេដ្ឋារចនាសម្ព័ន្ធ ADB នឹងជម្រុញឲ្យមានការរៀបចំគោលនយោបាយអំណោយផលសម្រាប់ការវិនិយោគ ក៏ដូចជាការកែទម្រង់លិខិតបទដ្ឋានគតិយុត្តិ និងស្ថាប័ន ដើម្បីឲ្យមានការរៀបចំសំណើគម្រោងសម្រាប់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដែលធនាគារអាចផ្តល់ហិរញ្ញប្បទានឲ្យបាន។"

មានការិយាល័យកណ្តាលនៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រ នៅអាស៊ី និងប៉ាស៊ីហ្វិច តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន កំណើនដែលធានាដល់ចីរភាពបរិស្ថាន និងសមាហរណកម្មតំបន់។ បង្កើតឡើងក្នុងឆ្នាំ ១៩៦៦ ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងប្រារព្ធខួបលើកទី ៥០ នៃភាពជាដៃគូអភិវឌ្ឍន៍របស់ខ្លួនក្នុងតំបន់។ ធនាគារនេះជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ប្រទេស ដែលក្នុងនោះ ៤៨ ប្រទេស មកពីតំបន់នេះ។

## ចំណុចសំខាន់ៗ ដែលត្រូវបានរំលេចក្នុងរបាយការណ៍នេះ៖

• ប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី ត្រូវការទុនវិនិយោគ ២៦ ទ្រីលានដុល្លារ ចាប់ពីឆ្នាំ ២០១៦ ដល់ ២០៣០ ឬ ១,៧ ទ្រីលានដុល្លារ ក្នុងមួយឆ្នាំ ប្រសិនបើតំបន់នេះចង់បន្តរក្សាកំណើនដែលខ្លួនសម្រេចបានកន្លងមក លុបបំបាត់ភាពក្រីក្រ និងឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ (ការប៉ាន់ប្រមាណកែសម្រួលទៅតាមអាកាសធាតុ)។ ដោយមិនគិតបញ្ចូលចំណាយលើការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ថវិកាដែលត្រូវការគឺ ២២,៦ ទ្រីលានដុល្លារ ឬ ១,៥ ទ្រីលានដុល្លារ ក្នុងមួយឆ្នាំ (តួលេខប៉ាន់ប្រមាណដើមគ្រា)។

• ក្នុងចំណោមតម្រូវការវិនិយោគសរុបដែលបានគិតបញ្ចូលការប្រែប្រួលអាកាសធាតុរួច ពីឆ្នាំ ២០១៦ ដល់ ២០៣០ ថវិកា ១៤,៧ ទ្រីលានដុល្លារ គឺសម្រាប់ថាមពល និង ៨,៤ ទ្រីលានដុល្លារ សម្រាប់គមនាគមន៍។ ការវិនិយោគលើវិស័យទូរគមនាគមន៍នឹងកើនឡើងដល់ ២,៣ ទ្រីលានដុល្លារ ហើយការចំណាយលើគម្រោងទឹកស្អាត និងអនាម័យ នឹងឡើងដល់ ៨០០ ប៊ីលានដុល្លារ ក្នុងរយៈពេលនេះ។

• តម្រូវការវិនិយោគដែលបានគិតគូរពីការប្រែប្រួលអាកាសធាតុរួច ៦១% នឹងត្រូវស្រូបយកដោយប្រទេសនៅអាស៊ីបូព៌ា រហូតដល់ឆ្នាំ ២០៣០។ ប៉ុន្តែ បើគិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក (ផសស) តំបន់ប៉ាស៊ីហ្វិចគឺនាំមុខអនុតំបន់ផ្សេងទៀត ដោយត្រូវការការវិនិយោគ ៩,១% នៃផសស បន្ទាប់មកអាស៊ីខាងត្បូង ៨,៨% អាស៊ីកណ្តាល ៧,៨% អាស៊ីអាគ្នេយ៍ ៥,៧% និងអាស៊ីបូព៌ា ៥,២% នៃផសស។

• តួលេខប៉ាន់ប្រមាណប្រចាំឆ្នាំ ដែលបានគិតគូរពីការប្រែប្រួលអាកាសធាតុរួច ១,៧ ទ្រីលានដុល្លារនេះ គឺច្រើនជាង ៧៥០ ប៊ីលានដុល្លារ ជាតួលេខដែល ADB ប៉ាន់ប្រមាណ កាលពីឆ្នាំ ២០០៩។ ការបញ្ចូលការវិនិយោគពាក់ព័ន្ធនឹងបរិស្ថាន គឺជាកត្តាធំមួយ ដែលនាំឲ្យមានការកើនតួលេខបែបនេះ។ កត្តាដែលរឹតតែសំខាន់ជាងនេះទៀត គឺការបន្តរីកចម្រើនយ៉ាងឆាប់រហ័ស ដែលគេបានព្យាករសម្រាប់តំបន់នេះ ដែលនាំឲ្យមានការបង្កើតនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធថ្មីៗ។ ការបញ្ចូលប្រទេសជាសមាជិក ADB ទាំង ៤៥ ដែលជាប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី បើធៀបជាមួយនឹង ៣២ ប្រទេស ក្នុងរបាយការណ៍ឆ្នាំ ២០០៩ និងការប្រើប្រាស់តម្លៃឆ្នាំ ២០១៥ ធៀបជាមួយនឹងតម្លៃឆ្នាំ ២០០៨ ក៏ជាមូលហេតុ ដែលនាំឲ្យមានការកើនតួលេខនេះផងដែរ។

• បច្ចុប្បន្ននេះ តំបន់នេះធ្វើការវិនិយោគប្រមាណជា ៨៨១ ប៊ីលានដុល្លារជារៀងរាល់ឆ្នាំ លើហេដ្ឋារចនាសម្ព័ន្ធ (សម្រាប់ ២៥ ប្រទេស ដែលមានទិន្នន័យគ្រប់គ្រាន់ ដែលគ្របដណ្តប់លើប្រជាជន ៩៦% នៃប្រជាជនសរុបក្នុងតំបន់នេះ)។ កង្វះទុនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលសំដៅលើភាពខុសប្លែកគ្នារវាងតម្រូវការវិនិយោគ និងកម្រិតនៃការវិនិយោគបច្ចុប្បន្ន គឺស្មើនឹង ២,៤% នៃផសស ដែលបានព្យាករ

ទុក (បានគិតគូរពីការប្រែប្រួលអាកាសធាតុរួច) សម្រាប់រយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ២០១៦ ដល់ ២០២០។

• សាធារណរដ្ឋប្រជាមានិតចិនខ្វះ ១,២% នៃផសស ក្នុងសេណារីយ៉ូ ដែលបានគិតគូរពីការប្រែប្រួលអាកាសធាតុរួច។ ប្រសិនបើគេមិនរាប់បញ្ចូលប្រទេសចិន កង្វះទុនវិនិយោគនោះគឺកើនឡើងខ្ពស់រហូតដល់ជាង ៥% នៃផសស ព្យាករ នៃប្រទេស ២៤ ផ្សេងទៀត។ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ អាចនាំមកនូវចំណូលបន្ថែម សម្រាប់បំពេញកង្វះខាតនេះបានប្រមាណជា ៤០% (ឬ ២% នៃផសស) សម្រាប់ប្រទេសទាំង ២៤ នេះ។ ដើម្បីឲ្យវិស័យឯកជនអាចបំពេញកង្វះខាតដែលនៅសេសសល់ (៣% នៃផសស) វិស័យនេះត្រូវបង្កើនទុនវិនិយោគពី ៦៣ ប៊ីលានដុល្លារបច្ចុប្បន្ននេះ ដល់រហូតដល់ ២៥០ ប៊ីលានដុល្លារ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០១៦ ដល់ ២០២០។

• ចាំបាច់ត្រូវមានការធ្វើកំណែទម្រង់លិខិតបទដ្ឋានគតិយុត្តិ និងកំណែទម្រង់ស្ថាប័ន ដើម្បីធ្វើយ៉ាងណាឲ្យហេដ្ឋារចនាសម្ព័ន្ធ កាន់តែមានភាពទាក់ទាញចំពោះវិនិយោគិនឯកជន និងបង្កើតនូវសំណើគម្រោងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដែលធនាគារអាចផ្តល់ហិរញ្ញបទានឲ្យបាន។ ប្រទេសនានាគួរអនុវត្តកំណែទម្រង់ពាក់ព័ន្ធនឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដូចជាអនុម័តលើច្បាប់ស្តីពីភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ធ្វើសាមញ្ញកម្មដំណើរការលទ្ធកម្ម និងដេញថ្លៃសម្រាប់គម្រោងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងបង្កើតអង្គភាពឯករាជ្យរបស់រដ្ឋាភិបាលទទួលបន្ទុកគម្រោងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ ការរៀបចំទីផ្សារមូលធនឲ្យបានល្អ ក៏ចាំបាច់ផងដែរ ដើម្បីជួយពាំនាំប្រាក់សន្សំយ៉ាងច្រើនរបស់តំបន់នេះ មកប្រើប្រាស់សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានផលិតភាព។

• ធនាគារអភិវឌ្ឍន៍ពហុភាគី បានផ្តល់ហិរញ្ញប្បទានដល់ប្រមាណជា ២,៥% នៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី។ បើមិនរាប់បញ្ចូលប្រទេសចិន និងឥណ្ឌា ការរួមចំណែករបស់ធនាគារទាំងនេះកើនឡើងលើស ១០%។ ការកើនឡើងនៃចំណែកហិរញ្ញប្បទានរបស់ ADB កំពុងផ្តោតលើគម្រោងហេដ្ឋារចនាសម្ព័ន្ធនៃវិស័យឯកជន។ ក្រៅពីការផ្តល់ហិរញ្ញប្បទាន ADB ក៏បំពេញតួនាទីសំខាន់នៅអាស៊ីផងដែរ តាមរយៈការចែករំលែកជំនាញឯកទេស និងចំណេះដឹង សម្រាប់កំណត់រករៀបចំ និងអនុវត្តគម្រោងល្អៗ។ ADB កំពុងពង្រីកប្រតិបត្តិ បញ្ចូលបច្ចេកវិទ្យាកាន់តែទំនើប និងកាន់តែស្អាត ទៅក្នុងគម្រោងនានា ក៏ដូចជាកំពុងធ្វើឲ្យនីតិវិធីនានាមានលក្ខណៈសាមញ្ញ។ ADB ក៏នឹងជម្រុញឲ្យមានការរៀបចំគោលនយោបាយអំណោយផលសម្រាប់ការវិនិយោគ និងការកែទម្រង់លិខិតបទដ្ឋានគតិយុត្តិ និងកំណែទម្រង់ស្ថាប័នផងដែរ។